# សេចក្តីប្រកាសព័ត៌មាន

## ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩

## ជប៉ុនគាំទ្រវគ្គបណ្តុះបណ្តាលលើកទឹកចិត្តយុវជន យុវនារីវ័យជំទង់នៅក្នុងខេត្តកោះកុង

រដ្ឋាភិបាលជប៉ុននឹងផ្តល់ជំនួយ តាមរយៈគ្រោងការណ៍នៃ *គម្រោងជំនួយឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន* នូវថវិកាចំនួន ២៩០.៣៩៦ ដុល្លាអាមេរិក ដល់អង្គការ CARE International Japan ។ កិច្ចសន្យាផ្តល់ ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ **ឯកឧត្តម កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និង **លោកស្រី អូដាឈិ ម៉ូតូកូ** អ្នកសម្រប- សម្រួលកម្មវិធី អង្គការ CARE International Japan ដើម្បីអនុវត្តន៍គម្រោង:

**គម្រោងគាំទ្រវគ្គបណ្តុះបណ្តាលលើកទឹកចិត្តយុវជន-យុវនារីវ័យជំទង់នៅក្នុងខេត្តកោះកុងនៃព្រះរាជាណាចក្រកម្ពុជា វគ្គទី២ (US$290,396)**

គម្រោងនេះគឺដើម្បីផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និង បង្កើតមុខជំនាញសម្រាប់យុវជន-យុវនារីវ័យជំទង់ ដែលពួកគេបានបោះបង់ការសិក្សាពីសាលារៀន ហើយរស់នៅក្នុងស្ថានភាពក្រីក្រ ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានផ្តោតលើយុវជន-យុវនារីវ័យជំទង់ ដែលរស់នៅក្នុងស្រុក មណ្ឌលសីមា និង ស្រុកបទុមសាគរ ខេត្តកោះកុង ជាខេត្តមួយដែលទទួលបានជំនួយតិចតួចពីអង្គការក្រៅរដ្ឋាភិបាល ។ តាមរយៈនេះ មានយុវជន-យុវនារីវ័យជំទង់ចំនួន ២៦០នាក់ នឹងទទួលប្រយោជន៍ពីគម្រោង ហើយរំពឹងថា ជាវិធីមួយដែលចូលរួមដល់ការសម្រេចចិត្តរបស់ភូមិពួកគេ ។ នេះជាគម្រោងវគ្គទី២ បន្តពីគម្រោង វគ្គទី១ ដែលបានអនុវត្តពីខែធ្នូ ឆ្នាំ២០០៧ មកដល់ ខែ ធ្នូ ឆ្នាំ២០០៨ ។

*គម្រោងជំនួយឥតសំណងអង្គការក្រៅរដ្ឋាភិបាលជប៉ុន* របស់រដ្ឋាភិបាលជប៉ុន បាន ចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដើម្បីជួយឧបត្ថម្ភដល់កិច្ច ប្រឹងប្រែងអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ ២០០២ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបជាង ៩.៩ លានដុល្លាអាមេរិក សម្រាប់អនុវត្តគម្រោងចំនួន ៤៧ ដោយផ្តោតជាពិសេសលើវិស័យអប់រំកីឡាបឋម សុខាភិបាល និង ការកំទេចចោលគ្រាប់មិនទាន់ផ្ទុះ។ អង្គការ CARE International Japan គឺជាអង្គការទទួលជំនួយទី២ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសំរាប់ ឆ្នាំសារពើពន្ធ ២០០៩ របស់ជប៉ុន (ពីខែ មេសា ឆ្នាំ ២០០៩ ដល់ ខែ មិនា ឆ្នាំ ២០១០) ។

ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ២១៧ ១៦១ ទូរសារ: ០២៣ ២១៤ ៣៣០
អ៊ីមែល: keikyou.eojc@online.com.kh
គេហទំព័រ: http://www.kh.emb-japan.go.jp